ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៥៧ អនក្រ - ឃ.ក

អនុក្រឹត្យ
ស្តីពី
ការកាត់ចេញពីផែនធីតម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគ មកជាដីឯកជនរបស់រដ្ឋ ទូទាំងដ្ឋីសរុបចំនួន ៥.៦៣១ ហិកតា នៅភូមិព្រៃធឌឹង ឃុំឆ្នាល់មាន់ ស្រុកតាស់ក្រឡ ខេត្តបាត់ដំបង និងធ្វើប្រធានកម្មជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងជាំជុះជាក់ស្តែង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨អនក្រ.បកចុះថ្ងៃទី០១ខែធ្នូ ឆ្នាំ២០០០ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការប្រឡងប្រណាំងកែលំអសោភ័ណភាពខេត្តទូទាំងប្រទេស
- បានឃើញសារាចរលេខ ០៥ សរ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០០ របស់រាជរដ្ឋាភិបាលស្តីពីសន្តិសុខ សុវ៉ៃ និងអាហារូបត្ថម្ភនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- តាមសំណើលេខ ១១៩៩ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- តាមសំណើលេខ ១២៦២ ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១..

ត្រូវបានកាត់ចេញពីផែនទីគម្របព្រៃឈើ និងធ្វើអនុបយោគមកជាដីឯកជនរបស់រដ្ឋ នូវចំណែកផ្ទៃដីសរុបចំនួន **៥.៦៣១ ហិកតា** (ប្រាំពាន់ប្រាំមួយរយសាមសិបមួយហិកតា) ដែលក្នុងនោះកាត់ដីចេញពីដីព្រៃសម្បទាន **ទំហំ ១.៧៨៩ ហិកតា** ពីក្រុមហ៊ុន **ឃ្លីសាគរ** (លិខិតលេខ ២២០ សជណ ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ១៩៩៨ របស់ទីស្តីការគណៈរដ្ឋមន្ត្រី) និងគម្របព្រៃឈើដែលមានដីកាដកហូត (ដីកាលេខ ១៨២ ដក.អនគ ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៦ របស់ខេត្តបាត់ដំបង) នូវផ្ទៃដីទំហំ **៣.៨៤៧ ហិកតា** មានទីតាំងស្ថិតនៅភូមិព្រៃទទឹង ឃុំឆ្នាល់មាន់ ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា ២..

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ដើម្បីធ្វើការគ្រប់គ្រងនិងប្រទានកម្មដោយផ្តល់នូវសិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិព្រៃទទឹង ឃុំឆ្នាល់មាន់ ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង លើក្បាលដីចំនួន **៩៦៨ ក្បាលដី** ជូនប្រជាពលរដ្ឋចំនួន **៥៩៨ (ប្រាំរយកៅសិបប្លន)** គ្រួសារ ព្រមទាំង ០២ ក្បាលដី ជាដីសាលារៀន និង ០២ ក្បាលដីជាដីស្រះទឹក។

មាត្រា ៣ .-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងសង្គមនៅក្នុងមូលដ្ឋាន។

មាត្រា ៤ .-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*